អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១០

# សេចក្តីប្រកាសព័ត៌មាន

**ថ្ងៃទី២៦ កក្កដា ២០១០ អង្គជំនុំជម្រះសាលាដំបូងប្រកាសសាលក្រម កាំង ហ្គេក អ៊ាវ** ហៅ **ឌុច**

សាលក្រមនៃសំណុំរឿងលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ទាក់ទងនឹងជនត្រូវចោទឈ្មោះ **កាំង ហ្គេក អ៊ាវ ហៅ ឌុច** និងត្រូវប្រកាសនៅថ្ងៃច័ន្ទ ទី ២៦ ខែ កក្កដា ២០១០ នៅក្នុងសាលសវនាការ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា( អ. វ. ត. ក) ។ អ. វ. ត. ក នឹងជូនដំណឹង ពីការបរិច្ឆេទនៃម៉ោងសម្រាប់ប្រកាសសាលក្រមនៅដ៏ខ្លីខាងមុខនេះ។

**កាំង ហ្គេក អ៊ាវ** ជាប្រធាននៃមន្ទីរសន្តិសុខដែលគេអោយឈ្មោះថា ទីស្នាក់ការនៃសាខាពិសេស របស់នគរបាលពិសេស (មន្ទីរសន្តិបាល ស-២១) នៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងកំលុងពេលដែលមានការប្រព្រឹត្តអំពើឃោឃៅ រវាងឆ្នាំ១៩៧៥ ដល់ ១៩៧៩ ។ គាត់ត្រូវបានគេចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

**កាំង ហ្គេក អ៊ាវ** ត្រូវបានឃាត់ខ្លួន ហើយនឹងបញ្ជូនមកកាន់កន្លែងឃុំឃាំងរបស់ អ. វ. ត. ក នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ក្រោយពេលបើកសវនាការបឋមនៅថ្ងៃទី១៧ និង ១៨ កុម្ភ: ឆ្នាំ២០០៩ សវនាការលើអង្គសេចក្តីបានប្រព្រឹត្តឡើងនៅថ្ងៃទី៣០ ខែមីនា ហើយនឹងបញ្ចប់ទៅវិញនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ នៅក្នុងកំលុងពេលនៃការជំនុំជម្រះក្តី ចំនួន ៧៧ ថ្ងៃ មានសាក្សីជំនាញចំនួន៩ នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុចំនួន ១៧ នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចារឹក ៧ នាក់ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ រូប បានឡើងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ រួមទាំងប្រជាជនជាង ៣ ១០០០ នាក់ បានចូលរួមស្តាប់នីតិវិធីនៃការជំនុំជម្រះក្តីនៅក្នុងសាលសាវនាការ។

**សវតានៃព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ:**

នៅក្នុងសេចក្តីប្រកាសព័ត៌មានដាច់ដោយឡែកផ្សេងទៀតសម្រាប់អ្នកសារព័ត៌មាន ទាក់ទងនឹងការសុំចុះឈ្មោះសុំបណ្ណព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីមកយកព័ត៌មាននៅ អ. វ. ត. ក ក៏ដូចជា សេវាដែលផ្តល់ជូនដោយ អ វ ត ក សំរាប់ប្រព័ន្ធផ្សព្វផ្សាយ សូមមេត្តាទាញយកព័ត៌មានទាក់ទងនឹងបញ្ហាខាងលើនេះ តាមគេហទំព័រដូចខាងក្រោម:

**ព័ត៌មានទាក់ទងនឹងសំណុំរឿង ០០១** http://www.eccc.gov.kh/khmer/cabinet/files/Case_Info_DUCH_Kh.pdf

**ព័ត៌មានទាក់ទងនឹងដីកា បញ្ជូនរឿងទៅជំនុំជម្រះក្តី កាំង ហ្គេក អ៊ាវ**
http://www.eccc.gov.kh/khmer/cabinet/courtDoc/101/Closing_Order_Final_in_Khmer_with_ABCD.pdf

**រូបថតផ្លូវការទាក់ទងនឹងការជំនុំជម្រះក្តី កាំង ហ្គេក អ៊ាវ**
http://www.flickr.com/photos/krtribunal/sets/72157623332496818/

និងរូបភាពវីដេអូដែលមាន Resolution ខ្ពស់ក្នុងថ្ងៃធ្វើសេចក្តីសន្និដ្ឋានចុងក្រោយដែល **កាំង ហ្គេក អ៊ាវ** បានសុំអោយអង្គជំនុំជម្រះសាលាដំបូងដោះលែងរូបគាត់:

សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:


លោក **រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 156
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោក **ឌីម សុវណ្ណារ៉ុម**
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855(0) 12 488 094
ទូរសារលេខ +855(0)23 219 841
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោក **ឡាស អូលសិន**
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855(0) 12 488 023
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6169
សារអេឡិចត្រូនិច olsenl@un.org

លោកស្រី **យូកូ ម៉េដា**
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855(0) 12 488 319
ទូរសារលេខ +855(0)23 219 841 លេខបន្ត 6139
សារអេឡិចត្រូនិច maeday@un.org